មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# របាយការណ៍បូកសរុបការងារប្រចាំឆ្នាំ ២០២២

| | |
|---|---|
| **ឈ្មោះស្ថាប័ន** | **មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក")** |
| **គោលដៅ** | ចក្ខុវិស័យរបស់ ម.ស.ម.ក គឺចង់ឃើញប្រទេសកម្ពុជាមានសន្តិភាពដែលពលរដ្ឋគ្រប់រូបអាចអនុវត្តសិទ្ធិមនុស្សមូលដ្ឋានដែលខ្លួនមានពីកំណើត ទទួលបាននីតិរដ្ឋដោយគ្មាននិទណ្ឌភាព ទទួលបានការគោរពស្មើភាពគ្នាដោយគ្មានការរើសអើង ទទួលបានការពង្រឹងភាពអង់អាចក្លាហានដើម្បីចូលរួមយ៉ាងពេញលេញក្នុងដំណើរការលទ្ធិប្រជាធិបតេយ្យ ព្រមទាំងទទួលបានចំណែកនៃអត្ថប្រយោជន៍ពីការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពរបស់ប្រទេសកម្ពុជា។ |
| **រយៈពេល** | ពីខែមករា ដល់ ខែធ្នូ ឆ្នាំ២០២២ |

ក្នុងអំឡុងពេលពីខែមករា ដល់ខែធ្នូ ឆ្នាំ២០២២ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") បានអនុវត្តសកម្មភាពការងាររបស់ខ្លួនដូចមានរៀបរាប់ខាងក្រោម ៖

## ១. សកម្មភាពការងារសំខាន់ដែលសម្រេចបានក្នុងឆ្នាំ២០២២

### *ការចេញឯកសារផ្សព្វផ្សាយ*

នៅក្នុងឆ្នាំ២០២២ នេះ ម.ស.ម.ក បានចេញឯកសារផ្សព្វផ្សាយសរុបចំនួន ១៤៧ ឯកសារដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្សក្នុងនោះរួមមានសេចក្តីថ្លែងការណ៍ លិខិតចំហ សេចក្តីថ្លែងការណ៍រួម សេចក្តីប្រកាសព័ត៌មានបន្ទាន់អំពីអ្នកការពារសិទ្ធិមនុស្ស កំណត់ត្រាសង្ខេប របាយការណ៍ស្រាវជ្រាវ សលាកបត្រព័ត៌មាន មេរៀនអប់រំសិទ្ធិមនុស្សអនឡាញ សៀវភៅមេរៀន ប័ណ្ណព័ត៌មាន ខិតប័ណ្ណព័ត៌មាន កម្រងសំណួរ និង កម្រងវីដេអូជាដើម។ ឯកសារទាំងនេះចេញផ្សាយក្នុងគោលបំណងតស៊ូមតិ យុទ្ធនាការលើកស្ទួយការគោរពសិទ្ធិមនុស្ស និងអប់រំផ្សព្វផ្សាយដើម្បីលើកកម្ពស់ការយល់ដឹងអំពីបញ្ហាសិទ្ធិមនុស្សរួមមានសេរីភាពមូលដ្ឋាន សិទ្ធិដីធ្លី ធុរកិច្ចនិងសិទ្ធិមនុស្ស និន្នាការភេទនិងអត្តសញ្ញាណយេនឌ័រការបង្ហាញទំនោរយេនឌ័រនិងលក្ខណៈភេទ សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា សិទ្ធិស្ត្រី សិទ្ធិជំនុំជម្រះដោយយុត្តិធម៌និងសិទ្ធិជនជាតិដើមភាគតិចជាដើម។ ឧទាហរណ៍នៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ ម.ស.ម.ក បានប្រកាសផ្សព្វផ្សាយជាផ្លូវការអំពីវេទិកាអប់រំសិទ្ធិមនុស្សស្តីពី

សេរីភាពសារព័ត៌មាននិងសិទ្ធិទទួលព័ត៌មាន ដែលរួមមានមេរៀនអនឡាញចំនួនពីរគឺ១)សេរីភាពសារព័ត៌មាន និង ២) សិទ្ធិទទួលព័ត៌មាន ដែលក្នុងនោះមានដូចជា មេរៀន វីដេអូតុក្កតា ប័ណ្ណព័ត៌មាន និងសំណួរសាកល្បង ដែលមានទាំងភាសាខ្មែរ និងអង់គ្លេស។ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ ម.ស.ម.ក ក៏បានប្រកាសផ្សព្វផ្សាយជាផ្លូវការអំពីវេទិកាអប់រំសិទ្ធិមនុស្សស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលក្នុងនោះមានមេរៀន និងសំណួរសាកល្បងចំនួន១៤ វីដេអូតុក្កតាចំនួន៥ និង ប័ណ្ណព័ត៌មានចំនួន១៦ ដែលមានទាំងភាសាខ្មែរ និងអង់គ្លេស។

ក្នុងចំណោមការចេញផ្សាយចំនួន១៤៧ ឯកសារ មាន ២៦ ឯកសារគឺជាវីដេអូដែលម.ស.ម.កបានផលិតឡើងសម្រាប់ការអប់រំផ្សព្វផ្សាយ។ សាធារណជនអ្នកអាចទស្សនាវីដេអូទាំងនេះនៅលើបណ្ដាញសង្គមយូធូបនិងទំព័រហ្វេសប៊ុក របស់ ម.ស.ម.ក។

## *ការឃ្លាំមើលនិងសង្កេតការណ៍សវនាការ*

ម.ស.ម.ក បានបន្តតាមដានអត្ថបទចេញផ្សាយតាមសារព័ត៌មាននានាក្នុងគោលបំណងទទួលបានព័ត៌មានទាន់ហេតុការណ៍ជុំវិញព្រឹត្តិការណ៍នានានិងបញ្ហាសំខាន់ៗមួយចំនួនដែលផ្ដោតទៅលើសិទ្ធិសេរីភាពមូលដ្ឋាន សិទ្ធិដីធ្លី ធុរកិច្ចនិងសិទ្ធិមនុស្ស សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា សិទ្ធិស្ត្រី និងស្ថានភាពសិទ្ធិមនុស្សដទៃទៀតនៅទូទាំងប្រទេស។ ជាសរុបក្នុងរយៈពេលនៃរបាយការណ៍នេះ ម.ស.ម.ក បានប្រមូលព័ត៌មានចំនួន ៦៩៦ អត្ថបទដែលចេញផ្សាយតាមសារព័ត៌មានពាក់ព័ន្ធនឹងសិទ្ធិសេរីភាពមូលដ្ឋាន សេរីភាពខាងការជួបប្រជុំ សេរីភាពខាងការបញ្ចេញមតិ សិទ្ធិដីធ្លី ធុរកិច្ចនិងសិទ្ធិមនុស្ស សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នានិងសិទ្ធិស្ត្រីជាដើម។

ម្យ៉ាងទៀត ជាផ្នែកនៃគម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្នុងឆ្នាំ២០២២ ម.ស.ម.ក បានសង្កេតការណ៍សវនាការក្នុងករណីព្រហ្មទណ្ឌចំនួន៥២១ ករណីនៅសាលាឧទ្ធរណ៍រាជធានីភ្នំពេញ សាលាឧទ្ធរណ៍ខេត្តត្បូងឃ្មុំ សាលាឧទ្ធរណ៍ខេត្តបាត់ដំបង និងសាលាឧទ្ធរណ៍ខេត្តព្រះសីហនុ និងករណីពាក់ព័ន្ធនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រចំនួន៣៦ ករណីនៅសាលាដំបូងខេត្តកំពង់ចាម និងខេត្តសៀមរាប។ លទ្ធផលនៃការសង្កេតការណ៍សវនាការករណីព្រហ្មទណ្ឌនៅសាលាឧទ្ធរណ៍ ម.ស.ម.ក បាននាំយកលទ្ធផលដំបូងនៃការសង្កេតសវនាទៅជួបពិភាក្សាជាមួយសាលាឧទ្ធរណ៍ខេត្តត្បូងឃ្មុំ សាលាឧទ្ធរណ៍ខេត្តបាត់ដំបង និងសាលាឧទ្ធរណ៍ខេត្តព្រះសីហនុ ដើម្បីយកធាតុចូលនិងការអនុវត្តកាន់តែប្រសើរឡើងចំពោះសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

## *យុទ្ធនាការ*

- *ទិវានារីអន្តរជាតិ ខែមីនា ឆ្នាំ២០២២*

ចាប់ពីថ្ងៃទី០៤ ដល់ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២១ ម.ស.ម.ក បានរៀបចំកម្មវិធីអបអរសាទរទិវានារីអន្តរជាតិ។ យុទ្ធនាការនេះរៀបចំឡើងក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងក្នុងចំណោមសាធារណៈជនអំពីការចូលរួមរបស់ស្ត្រីនៅក្នុងសង្គមស៊ីវិលន និងបង្ហាញពីបញ្ហាប្រឈមដែលស្ត្រីចូលរួមនៅក្នុងសង្គមឬការចូលរួមជា

សាធារណៈនៅក្នុងប្រទេសកម្ពុជា។ នៅក្នុងយុទ្ធនាការ ម.ស.ម.កបានរៀបចំសកម្មភាពជាច្រើនរួមមានទាំងការកៀរគឲ្យសាធារណៈជនចូលរួមឆ្លើយសំណួរតាមអនឡាញ ការចេញផ្សាយកាលប្បវត្តកូដកម្មរបស់បុគ្គលិកណាហ្គា ការចេញផ្សាយពី ខិត្តប័ណ្ណព័ត៌មានស្តីពីជនរងគ្រោះពីអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងសវនាការ ការផ្សាយជជែកផ្ទាល់កម្មវិធីវិទ្យុ និងការរៀបចំព្រឹត្តិការណ៍ដើម្បីអបអរសារទរទិវានារីអន្តរជាតិ។

- *<u>យុទ្ធនាការ១៦ ថ្ងៃដើម្បីបញ្ចប់អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងទិវាសិទ្ធិមនុស្សអន្តរជាតិ</u>*

នៅខែវិច្ឆិកា និងខែធ្នូ ឆ្នាំ២០២២ ម.ស.ម.ក បានរៀបចំទិវាអន្តរជាតិសំខាន់ៗរបស់អង្គការសហប្រជាជាតិ។ នៅថ្ងៃទី២៥ ខែវិច្ឆិកា គឺជាទិវាអន្តរជាតិដើម្បីបញ្ចប់អំពើហិង្សាលើស្ត្រី។ យុទ្ធនាការ១៦ ថ្ងៃនេះមានគោលបំណងផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងពីអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅក្នុងសហគមន៍ និងដើម្បីទាមទាឲ្យរដ្ឋាភិបាលកម្ពុជាចាត់វិធានការជាបន្ទាន់និងច្បាស់លាស់ដើម្បីបញ្ចប់អំពើហិង្សាលើស្ត្រី និងលើកកម្ពស់សមភាពយេនឌ័រនៅកម្ពុជា។ ម.ស.ម.ក បានរៀបចំយុទ្ធនាការនេះចាប់ពីថ្ងៃទី២៥ ខែវិច្ឆិកា រហូតដល់ទិវាសិទ្ធិមនុស្សអន្តរជាតិនាថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២ ដែលជាទិវាសំខាន់ដើម្បីប្រារព្ធខួបនៃការប្រកាសប្រើប្រាស់សេចក្តីប្រកាសជាសាកលអំពីសិទ្ធិមនុស្ស ដែលជាឯកសារដ៏សំខាន់ពាក់ព័ន្ធនឹងក្របខណ្ឌសិទ្ធិមនុស្សអន្តរជាតិ និងជាសិទ្ធិមនុស្សមូលដ្ឋានរបស់បុគ្គលគ្រប់រូប។ ប្រធានបទសម្រាប់ទិវាសិទ្ធិមនុស្សអន្តរជាតិឆ្នាំ២០២២ ក្តីសង្ឃឹម ជីវិតរស់នៅក្នុងភាពថ្លៃថ្នូ មានសេរីភាព សមភាពនិងយុត្តិធម៌។ យុទ្ធានាការរបស់ម.ស.ម.ក បានរៀបចំនូវសកម្មភាពជាច្រើនបន្តបន្ទាប់នៅលើបណ្តាញផ្សព្វផ្សាយសង្គម ដើម្បីទាក់ទាញឲ្យមានការចូលរួមពីសាធារណជនផងដែរ។ សកម្មភាពទាំងនោះរួមមានរួមមានទាំងការកៀរគឲ្យសាធារណៈជនចូលរួមឆ្លើយសំណួរតាមអនឡាញ ការចេញផ្សាយបច្ចុប្បន្នភាពកាលប្បវត្តកូដកម្មរបស់បុគ្គលិកណាហ្គា ការចេញផ្សាយខិត្តប័ណ្ណព័ត៌មានស្តីពីវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍របស់រដ្ឋាភិបាលទៅលើយន្តការនៃការត្រួតពិនិត្យជាសាកលតាមកាលកំណត់អំពីសិទ្ធិស្ត្រី ការផ្សាយជជែកផ្ទាល់កម្មវិធីវិទ្យុ និងការរៀបចំព្រឹត្តិការណ៍ប្រកួតទាត់បាល់ពានរង្វាន់សិទ្ធីមនុស្សដើម្បីអបអរសារទរទិវាសិទ្ធិមនុស្សអន្តរជាតិលើកទី៧៤ និងការចេញផ្សាយបណ្ណព័ត៌មានអំពីព្រឹត្តិការណ៍សិទ្ធិមនុស្សសំខាន់នៅក្នុងឆ្នាំ២០២២។

***<u>កម្មវិធីវិទ្យុ</u>***

នៅឆ្នាំ២០២២ ម.ស.ម.ក បានផលិតកម្មវិធីផ្សាយផ្ទាល់កិច្ចពិភាក្សាតាមវិទ្យុចំនួន ១៥៣ លើកដោយផ្តោតលើប្រធានបទនានាតាមវិស័យនីមួយៗដូចមានដីធ្លី ធុរកិច្ចនិងសិទ្ធិមនុស្ស សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា និន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ ការពិភាក្សាអំពីច្បាប់និងការវិភាគប្រចាំសប្តាហ៍។ ក្នុងកម្មវិធីពិភាក្សាទាំងនោះសុទ្ធតែមានការអញ្ជើញវាគ្មិនចម្រុះដែលមកពីអង្គការសង្គមស៊ីវិល គណៈមេធាវី និងរដ្ឋាភិបាលដើម្បីចូលរួមចែករំលែកនូវគំនិតយោបល់ក្នុងកិច្ចពិភាក្សា។ រាល់កម្មវិធីពិភាក្សាទាំងអស់ក៏មានផ្សព្វផ្សាយបន្តផ្ទាល់នៅលើគេហទំព័រហ្វេសប៊ុករបស់ម.ស.ម.ក ផងដែរ ដែលទទួលបានព័ត៌មាន

ចំនួន១០២ ៨៥៧ ២២៣ ទទួលបានការចុច Like ចំនួន ១៩៩៣៤ ចែករំលែកបន្តចំនួន ៥១៧៩ ចូលទស្សនា ចំនួន៩៨៦ ៧៨៤ និងផ្តល់មតិយោបល់ចំនួន៣៣២១។

## ២. ការប្រឈមនិងបទពិសោធន៍

ក្នុងឆ្នាំ២០២២ ម.ស.ម.ក នៅតែបានប្រឈមបញ្ហារីករាលដាលនៃជំងឺកូវីដ-១៩ ថ្វីត្បិតតែការរីករាលដាលនេះបានរួមតូច។ យ៉ាងណាក្តី ដោយសារការរីករាលដាលនៅឆ្នាំ២០២១ កើតឡើងច្រើន ដូចនេះសកម្មភាព ឬកម្មវិធីនានាដែលបានគ្រោងរៀបចំដោយផ្ទាល់នៅឆ្នាំ២០២១ ត្រូវបានយកមកអនុវត្តយ៉ាងច្រើននៅឆ្នាំ២០២២ ។

## ៣. យេនឌ័រ និងគោលការណ៍ផ្អែកលើសិទ្ធិជាមូលដ្ឋាន

ម.ស.ម.ក នៅតែអនុវត្តសកម្មភាពការងាររបស់ខ្លួនដើម្បីធានាយ៉ាងណាដើម្បីឲ្យមានសមភាពយេនឌ័រ ជាពិសេសសការចូលរួមរបស់ស្ត្រី។ នៅគ្រប់ពេលទាំងអស់ ម.ស.ម.ក តែងតែលើកឡើងពីស្ថានភាពផ្លូវច្បាប់ស្មើភាពគ្នារវាងបុរស ស្ត្រី និងអ្នកស្រឡាញ់ភេទដូចគ្នាទាក់ទងនឹងសិទ្ធិមនុស្ស។

លើសពីនោះ ម.ស.ម.ក បានរៀបចំព្រឹត្តិការណ៍សំខាន់មួយចំនួនដើម្បីលើកកម្ពស់ស្ត្រី និងសមភាពយេនឌ័រនៅក្នុងឱកាសនៃទិវានារីអន្តរជាតិ ០៨ មីនា ឆ្នាំ២០២២ យុទ្ធនាការ ១៦ ថ្ងៃដើម្បីបញ្ឈប់អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងនៅតែបន្តផ្តល់ជំនួយផ្នែកច្បាប់ មនុស្សធម៌ និងផ្លូវចិត្តតាមលទ្ធភាពដែលអាចធ្វើទៅបានដល់អ្នកការពារសិទ្ធិមនុស្សជាស្ត្រី និងអ្នកស្រឡាញ់ភេទដូចគ្នាដែលបានប្រឈមនឹងអំពើហិង្សា ការយាយី និងការគំរាមកំហែងដោយសារការងាររបស់ពួកគេ៕

## ៤. ឧបសម្ព័ន្ធ

ឯកសារចេញផ្សាយសំខាន់ៗរបស់ ម.ស.ម.ក រួមមាន ៖

- បណ្ណព័ត៌មានស្តីអំពី សេរីភាពសារព័ត៌មាននិងសិទ្ធិទទួលព័ត៌មាន ចំនួន២ ច្បាប់
- សៀវភៅមេរៀនស្តីអំពីសេរីភាពខាងការបញ្ចេញមតិ សិទ្ធិទទួលព័ត៌មាននិង ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ចំនួន២ ច្បាប់
- សៀវភៅមេរៀនស្តីអំពីសេរីភាពសារព័ត៌មាននិងសិទ្ធិទទួលព័ត៌មាន ចំនួន២ ច្បាប់
- សៀវភៅមេរៀនស្តីអំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ចំនួន ២ ច្បាប់
- បណ្ណព័ត៌មានស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ចំនួន១ ច្បាប់ (១៦ បណ្ណ)

--- ចប់ ---